multicultural health communication

NSW GOVERNMENT | Health

Khmer
[DOH-7095]

# ការឆ្លងវីរុស បារម៉ា ហ្វ័រេស្ត (Barmah Forest)

## Barmah Forest virus infection

### តើវីរុស Barmah Forest ជាអ្វី?

- វីរុស Barmah Forest ជាមេរោគមួយប្រភេទដែលអាចឆ្លងទៅមនុស្សតាមរយៈមូសខាំ។
- ការឆ្លងវីរុស Barmah Forest នៅគ្រាអតីតកាល អាចផ្តល់នូវការបង្ការទប់ស្កាត់ការឆ្លងនៅពេលអនាគត។
- វីរុស Barmah Forest ជាប់ពូជសន្តានជាមួយនឹងវីរុស Ross River ។

### តើវីរុស Barmah Forest ឆ្លងរាលដាលយ៉ាងដូចម្តេច?

- វីរុសនេះឆ្លងតាមរយៈប្រភេទមូសញីមួយចំនួន។
- មូសញីបឺតឈាមពីសត្វនិងមនុស្ស ។ បើសិនវាបឺតឈាមពីសត្វដែលបានផ្ទុកមេរោគ មូសនោះអាចក្លាយទៅជាមូសផ្ទុកមេរោគ ។ បន្ទាប់មកវីរុសអាចឆ្លងបន្តទៅសត្វឬមនុស្សផ្សេងទៀតនៅពេលមូសដែលមានផ្ទុកមេរោគនោះខាំបឺតឈាមម្តងទៀត ។
- ពូជសត្វជាច្រើនដូចជាកង់កូរូ និង វ៉ល់ឡាប៊ី (Wallabies) ត្រូវបានគេគិតថា ជាសត្វសំខាន់ៗដែលពាក់ព័ន្ធនៅក្នុងខួបនៃការឆ្លងជម្ងឺនេះ ។
- វីរុសនេះមិនឆ្លងពីមនុស្សម្នាក់ទៅម្នាក់ផ្សេងទៀតទេ ។

### តើជម្ងឺបង្កដោយវីរុស Barmah Forest មានរោគសញ្ញាអ្វីខ្លះ ?

- មនុស្សជាច្រើនដែលមានផ្ទុកវីរុសនេះនឹងមិនមានចេញជារោគសញ្ញាអ្វីទេ។
- រោគសញ្ញានៃជម្ងឺបង្កដោយវីរុស Barmah Forest ស្រដៀងគ្នានឹងជម្ងឺបង្កដោយវីរុស Ross River ដែរ។
- បណ្តារោគសញ្ញាដូចជម្ងឺផ្តាសាយអាចកើតមាន, ដោយមានឡើងកំដៅខ្លួន, រងារញាក់, ឈឺក្បាល, ឈឺសាច់ដុំនិងសន្លាក់
- មនុស្សខ្លះអាចមានហើមសន្លាក់និងរឹងសន្លាក់ជាពិសេសកត់សំគាល់ឃើញនៅពេលព្រឹក ។
- ជួនកាលមានឡើងកន្ទួល, ជាទូទៅនៅលើខ្លួនឬដៃជើង ។ ជាទូទៅស្នាមកន្ទួលនេះបាត់ទៅវិញ ក្រោយពី ៧-១០ ថ្ងៃ ។
- មានអារម្មណ៍ហេវហត់, អស់កំលាំងនៅក្នុងពេលកំពុងមានជម្ងឺ ដែលអាចប៉ះពាល់ដល់បែបបទនៃការរស់នៅ និងការអនុវត្តការងារ ។

**តើរោគសញ្ញាទាំងនេះកើតឡើងឆាប់រហ័សប៉ុណ្ណាបន្ទាប់ពីមូសដែលមានផ្ទុកមេរោគបានខាំ?**

- រោគសញ្ញាទាំងនេះកើតឡើងក្នុងរវាង ៥ ទៅ ២១ ថ្ងៃប៉ុន្តែជាធម្មតាពី ៧ ទៅ ១០ ថ្ងៃបន្ទាប់ពីមូសដែលផ្ទុកមេរោគបានខាំ ។

**តើជម្ងឺនេះឋិតថេរយូរប៉ុណ្ណា?**

- មនុស្សភាគច្រើននឹងជាសះស្បើយទាំងស្រុងក្នុងរយៈពេល ២ ឬ ៣ អាទិត្យ ។ មនុស្សផ្សេងទៀតអាចជួបប្រទះរោគសញ្ញាម្តងបាត់ម្តងឃើញ ក្នុងរយៈពេលលើសពី ៣ ខែ ។ ក្នុងករណីដ៏កំរ, មនុស្សខ្លះអាចមានរោគសញ្ញារហូតលើសពីមួយឆ្នាំ ។
- គេអាចសង្ឃឹមទុកថា ជម្ងឺនេះអាចជាសះស្បើយទាំងស្រុងបាន ។

**តើគេព្យាបាលជម្ងឺបង្កដោយវីរុស Barmah Forest យ៉ាងដូចម្តេច ?**

- ពុំមានការព្យាបាលជាក់លាក់សំរាប់ជម្ងឺបង្កដោយវីរុស Barmah Forest នោះទេ ។
- វេជ្ជបណ្ឌិតរបស់លោកអ្នកនឹងអាចជួយលោកអ្នក ក្នុងការបន្ធូរនូវការធ្វើទុក្ខនៃរោគសញ្ញាទាំងនោះ។
- ការសំរាកគ្រប់គ្រាន់រួមជាមួយការធ្វើលំហាត់ប្រាណសមល្មម និងការបរិភោគអាហារផ្តល់អំណោយផលដល់សុខភាព អាចជួយឲ្យលោកអ្នកឆាប់បានជាសះស្បើយ។

**តើខ្ញុំដឹងដោយរបៀបណា ថាខ្ញុំមានជម្ងឺបង្កដោយវីរុស Barmah Forest ?**

បើសិនលោកអ្នកមានរោគសញ្ញាសូមទៅជួបវេជ្ជបណ្ឌិតរបស់លោកអ្នក ដែលអាចបញ្ជូនឲ្យធ្វើតេស្តឈាមដើម្បីធ្វើរោគវិនិច្ឆ័យជម្ងឺបង្កដោយវីរុស Barmah Forest ។

**តើគេអាចបង្ការជម្ងឺបង្កដោយវីរុស Barmah Forest បានឬទេ?**

- គន្លឹះនៃការបង្កាគឺការជៀសវាងកុំឲ្យមូសខាំជាពិសេសក្នុងរដូវក្តៅ និងរដូវស្លឹកឈើជ្រុះ។
- ជៀសវាងចេញក្រៅក្រោយពេលរសៀលនិងព្រលប់ ។ ជាទូទៅមូសមានសកម្មភាពខ្លាំងក្នុងរយៈពេល ១-៣ ម៉ោងបន្ទាប់ពីថ្ងៃលិច និងម្តងទៀតនៅពេលជិតភ្លឺ ។
- នៅពេលចេញក្រៅត្រូវស្លៀកពាក់សំលៀកបំពាក់រលុងៗ, ពណ៌ស្រាលព្រឿងៗដោយគ្របដៃនិងជើងឲ្យជិត ហើយប្រើថ្នាំបណ្តេញសត្វល្អិត ដែលមានផ្ទុកជាតិគីមី ឌីយេទីលតូលុយអាមីត (DEET) ឬពីការីឌីន (Picaridin) ។
- ដាក់សំណាញ់ការពារនៅគ្រប់បង្អួចនិងទ្វារទាំងអស់និងបំពង់ផ្សែង (នៅពេលមិនប្រើ) និងរក្សាវាឲ្យមានដំណើរការល្អ ។
- ប្រើថ្នាំសំលាប់សត្វល្អិតនៅកន្លែងដេក ដោយធ្វើតាមការណែនាំ
- ត្រូវយកសំភារៈដាក់ទឹកបើកចំហទាំងអស់ចេញពីបរិវេណផ្ទះ ដើម្បីកុំឲ្យមូសពងដាក់ ។ គ្របធុង/អាងដាក់ទឹកទាំងអស់ដោយគំរបធ្វើពីសំណាញ់ដែកយ៉ាងញឹក ដើម្បីបង្កាកុំឲ្យមូសពងដាក់ ។
- នៅពេលបោះជំរុំត្រូវប្រុងប្រយ័ត្ន ដូចជាប្រើសំណាញ់បង្ការរុយលើការ៉ាវាន់ និងសំពត់តង់ ហើយដេកក្នុងមុងដែលមូសចូលមិនបាន។
- ជាពិសេសត្រូវការពារនៅពេលនេសាទ ដោយត្រូវអនុវត្តនូវការប្រុងប្រយ័ត្នផ្ទាល់ខ្លួនដើម្បីជៀសវាងមូសខាំ។

## ព័ត៌មានបន្ថែម – ផ្នែកសុខភាពសាធារណៈ (Public Health) នៅក្នុងរដ្ឋ NSW

**1300 066 055**

www.health.nsw.gov.au